ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អូររុន
## រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

ឈ្មោះសហគមន៍នេសាទ ៖ អូររុន
ភូមិ ៖ អូររុន
ឃុំ ៖ អូរស្វាយ
ស្រុក ៖ បុរីអូរស្វាយសែនជ័យ
ខេត្ត ៖ ស្ទឹងត្រែង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អូររុន
# រយៈពេល ៣ ឆ្នាំ ( តុលា ២០១៩ - កញ្ញា ២០២២ )

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | អូររុន |
| ភូមិ | ៖ | អូររុន |
| ឃុំ | ៖ | អូរស្វាយ |
| ស្រុក | ៖ | បុរីអូរស្វាយសែនជ័យ |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ខែមករា ឆ្នាំ២០១៩

# មាតិកា


១.ស្ថានភាពទូទៅ ............ ១
២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម ............ ២
ក.ប្រជាពលរដ្ឋ ............ ២
ខ.មុខរបរ ............ ២
៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ ............ ២
ក.ទីតាំង ............ ២
ខ.ដែននេសាទ ............ ៣
ខ.១.ទន្លេមេគង្គ ............ ៣
ខ.២.អូរ ............ ៣
ខ.៣.កោះ ............ ៣
គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ............ ៤
ឃ.ធនធានជលផល ............ ៤
ឃ.១.ប្រភេទត្រី ............ ៤
ឃ.២.ប្រភេទវារីសត្វ៖ ............ ៥
ឃ.៣.ប្រភេទបក្សី៖ ............ ៥
ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖ ............ ៥
៤.ការធ្វើនេសាទ ............ ៥
ក.អ្នកនេសាទ ............ ៥
ខ.ឧបករណ៍នេសាទ ............ ៥
គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ............ ៦
៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............ ៦
ក.ទស្សនៈវិស័យ ............ ៦
ខ.គោលបំណងរួម ............ ៦
គ.គោលបំណងជាក់លាក់ ............ ៦
ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............ ៧
ឃ.១.ធនធានជលផល និងអេកូឡូស៊ី ............ ៧
ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ............ ៧
ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ............ ៧
ឃ.១.៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ............ ៨
ឃ.១.៤.ផែនការគ្រប់គ្រងព្រៃលិចទឹក ............ ៨
ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ ............ ៩
ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល ............ ៩

ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........................................ ១០
ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ........................................ ១០
ឃ.២.៤. ផែនការបង្ការ និងបន្សុំាការប្រែប្រួលអាកាសធាតុ ........................................ ១០
ឃ.៣.ការងារគ្រប់គ្រង ........................................ ១១
ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ........................................ ១១
ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ........................................ ១១
ឃ.៣.៣.ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ........................................ ១១
ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........................................ ១២
ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........................................ ១២
ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........................................ ១៣
ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖ ........................................ ១៣
ច.យុទ្ធសាស្ត្រ ........................................ ១៣
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អូររុនរយៈពេល ៣ ឆ្នាំ (១០/២០១៩ ដល់៩/២០២២)** ........................................ ១៥
**តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ (តុលា ២០១៩- កញ្ញា ២០២២)** ........................................ ២០

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទអូររុន ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០២ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រយៈពេល៣ឆ្នាំ គឺចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ សហគមន៍នេសាទនេះ មានទីតាំងស្ថិតនៅក្នុងភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន៥៤២នាក់ ស្រីចំនួន២៥៩នាក់ ស្មើនឹង១៨៨គ្រួសារ និងមានគណៈកម្មការចំនួន០៧នាក់ ស្រីចំនួន០៣នាក់។ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមក សហគមន៍នេសាទនេះបានអនុវត្តសកម្មភាពសំខាន់ៗរួមមានដូចជា ការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ ធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ជីឈ្មោះសមាជិក រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងការរៀបចំក្រុមល្បាត ព្រមទាំងចូលរួមប្រជុំ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗ ព្រមទាំងចុះល្បាតក្នុងកន្លែងនេសាទសហគមន៍ជាប្រចាំ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងគឺ៖

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមាន៖ ធនធានត្រីថយចុះគ្រប់ប្រភេទ ការនេសាទនៅរដូវត្រីពងកូន អ្នកប្រព្រឹត្តបទល្មើសនេសាទមានគ្នាច្រើន និងសំភារៈទំនើប និងមានល្បឿនលឿនជាងសហគមន៍នេសាទ បាក់ច្រាំងមាត់ទន្លេ ទឹកឡើងចុះមិនទៀងទាត់ មានស្លែច្រើន ព្រៃលិចទឹកដួលរលំដោយសារកំលាំងទឹកហូរខ្លាំង មានកំណើនអ្នកនេសាទមកពីក្រៅសហគមន៍ច្រើន

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋរួមមាន ប្រជាពលរដ្ឋខ្វះមុខរបរចិញ្ចឹមជីវិត កំណើនប្រជាពលរដ្ឋខ្វះប្រភពទឹកធ្វើស្រែ ភ្លៀងធ្លាក់មិនទៀងទាត់ កំដៅឡើងខ្លាំងធ្វើអោយសត្វចិញ្ចឹមឈឺ និងងាប់ ផលដំណាំទទួលបានទិន្នផលតិច ខ្វះចំណេះដឹងនិងជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ តម្លៃផល ផលិតផលមិនស្ថិតស្ថេរ និងទីផ្សារនៅឆ្ងាយពីភូមិ ខ្វះមធ្យោបាយដឹកផលិតផល និងខ្វះខាតហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវ ស្ពាន លូ ជាដើម

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងរួមមាន ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់ឧបករណ៍ឆក់ ប្រើសារធាតុពុល គប់គ្រាប់) ប្រជាពលរដ្ឋមិនហ៊ានរាយការណ៍ពេលឃើញបទល្មើស កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធមិនទាន់រលូន មិនសូវមានការលើកទឹកចិត្តដល់គណកម្មការសហគមន៍នេសាទ ប្រជាពលរដ្ឋមិនយល់ពីសារៈប្រយោជន៍នៃសហគមន៍នេសាទ ខ្វះមធ្យោបាយចុះល្បាត និងថវិកា គ្មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់ស្គាល់ពីតួនាទីរបស់ខ្លួន ហើយគណៈកម្មការសហគមន៍នេសាទ និងប្រជាជនមិនទាន់យល់ពីច្បាប់ស្តីពីជលផល ច្បាប់ស្តីពីតំបន់ការពារ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ។

## ២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋក្នុងភូមិអូររុន សរុប១.០១៥នាក់ ស្រី៤២០នាក់ ស្មើ២១០គ្រួសារ ក្នុងនោះមានជនជាតិខ្មែរចំនួន ១០០%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន១០០%។

ប្រជាពលរដ្ឋក្នុងភូមិអូររុន មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីជាមេគ្រួសារ/ស្រីមេម៉ាយមាន៣៤នាក់
- ចំនួនបុរសពោះម៉ាយមាន ០៤នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន០៧នាក់ ស្រី០១នាក់
- ចំនួនចាស់ជរាមាន១០នាក់ ស្រី០៦នាក់
- ចំនួនអ្នកមានជម្ងឺរ៉ាំរ៉ៃមាន០៣នាក់ ស្រី០២នាក់
- កម្រិតសិក្សាអប់រំមាន អ្នកមិនចេះអក្សរមានចំនួន១៦៣នាក់ ស្រី៩០នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន ២៥៦នាក់ ស្រី៩២នាក់ កម្រិតអនុវិទ្យាល័យចំនួន២៦នាក់ ស្រី១២ នាក់។

### ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន១៨៨គ្រួសារ
- អ្នកធ្វើស្រែចំនួន១៥០គ្រួសារ ដែលមានទំហំដីចំនួនសរុប ១៨០ ហិកតា
- ធ្វើចំការចំនួន១៨៨ គ្រួសារ ដែលមានទំហំដីចំនួនសរុប១៥ហិកតា (ស្រូវ ពោត ដំឡូង ចន្ទីរ ក្រូចឆ្មា.....)
- ដាំបន្លែជាលក្ខណៈគ្រួសារ៩០គ្រួសារ ដែលមានទំហំសរុប ១២ហិកតា
- ជាងកាត់ដេរ ៣ គ្រួសារ
- លក់ដូរជាអាជីពចំនួន ០៦ គ្រួសារ
- ប្រមូលទិញផលនេសាទ ០២គ្រួសារ
- ធ្វើកម្មករចំនួន៨គ្រួសារ
- ជាងកាត់សក់ ៣គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ១៧០ គ្រួសារ ស្មើ ៨៥%
- ជាងទូក ០២ គ្រួសារ
- ពេទ្យសត្វ ០១ គ្រួសារ
- ចំណាកស្រុកទៅក្រៅប្រទេស ២៥ នាក់ ស្ត្រី១៥នាក់
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួន១១០ គ្រួសារ ក្នុងនោះរួមមានប្រហុក ត្រីប្រៃ (មួយគ្រួសារអាច ផលិតបានពី១០ គីឡូក្រាមទៅ ៤០គីឡូក្រាមក្នុង១ឆ្នាំ)។

## ៣.តំបន់នេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងតំបន់នេសាទសហគមន៍

### ក.ទីតាំង

តំបន់នេសាទសហគមន៍អូររុន ជាដែននេសាទសាធារណៈរបស់រដ្ឋ។ តំបន់នេសាទសហគមន៍អូររុនមានទំហំ ១.៣៣៦ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

**មានព្រំប្រទល់៖**

- ខាងជើងទល់នឹង អូរក្តុលព្រំប្រទល់ភូមិអូរស្វាយ និងព្រំប្រទល់ភូមិអូររុន ក្នុងឃុំអូរស្វាយ
- ខាងត្បូងទល់នឹង ដែនសហគមន៍នេសាទភូមិវ៉ឺនសៀន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ
- ខាងកើតទល់នឹង ភូមិអូររុន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង
- ខាងលិចទល់នឹង ដែនសហគមន៍នេសាទភូមិកោះឈើទាលតូច ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ។

**ខ. ដែននេសាទ**

កន្លែងសហគមន៍នេសាទអូររុន មានវិសាលភាពនៅក្នុងទន្លេមេគង្គ ហើយមានអូរចំនួន០៨ កោះចំនួន១៨ និងអន្លង់ចំនួន០៨។

**ខ.១.ទន្លេ**

| ឈ្មោះទន្លេ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ៧.៨០០ | ពេញមួយឆ្នាំ |

**ខ.២.អូរ**

| ឈ្មោះអូរ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| អូរក្តុល | ១.០០០ | ខែ ០៦-ខែ ១១ |
| អូររុន | ២០០ | ខែ ០៧-ខែ ១០ |
| អូរតាហាក់ | ២០០ | ខែ ០៧-ខែ ១០ |
| អូរតាឈី | ២០០ | ខែ ០៧-ខែ ១០ |
| អូរល្វា | ៣.០០០ | ខែ ០៦-ខែ ១១ |
| អូរយេ | ២.០០០ | ខែ ០៦-ខែ ១១ |
| អូរតាគឹម | ៣០០ | ខែ ០៧-ខែ ១០ |

**ខ.៣.កោះ**

| ឈ្មោះកោះ | ទទឹង និងបណ្តោយ (ម៉ែត្រ) | ទំហំសរុប (ហិកតា) |
|---|---|---|
| កោះឱឡឹក | ៦០ x ៣០០ | ១,៨ |
| កោះស្រឡៅ | ២.៥០០ x ១.៥០០ | ៣,៧៥ |
| កោះវែង | ៨០ x ៩០០ | ៧,២០ |
| កោះភ្នំ | ៧៥០ x ១៥០ | ១១,២៥ |
| កោះស្វាយ | ៨០ x ៦០ | ០,៤៨ |
| កោះវ៉ឺនសូត្រ | ៧០ x ៥០០ | ៣,៥០ |
| កោះយាយណាំង | ៨០ x ៤០០ | ៣,២០ |
| កោះថ្នាំ | ៦០ x ៦០ | ០,៣៦ |
| កោះសុនឡៃ | ១០០ x ៥០ | ០,៥០ |

| | | |
|---|---|---|
| កោះគគី | ១.៥០០ x ១៥០ | ២២,៥០ |
| កោះអូន | ១២០ x ៨០ | 0,៩៦ |
| កោះប៉េតា | ៥០០ x ៥០ | ២,៥០ |
| កោះតាចក់ | ៧០ x ៣០ | 0,២១ |
| កោះវៃ | ២០០x ៣០ | 0,៦០ |
| កោះវ៉ើនផូ (កោះអន្លង់ផូ) | ២៣០ x ៦០ | ១,៣៨ |
| កោះឃុន | ៦០ x ៣០ | 0,១៨ |
| កោះអន្លង់ត្រីក្រាយ (កោះប៊ុងប៉ាតង) | ៥០០ x ២០០ | ១០,00 |
| កោះឱឡឹក | ៦០ x ៣០០ | ១,៨០ |

**ខ.៤.អន្លង់**

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវវស្សា (ម៉ែត្រ) |
| អន្លង់អាចម៍ក្រពើ | ២៥០ x ៨០ | ២.០០០ | ៥០ | ៤០ |
| អន្លង់បីជួរធំ | ១៥០ x 100 | ១.៥០០ | ៣៥ | ២៥ |
| អន្លង់បីជួរតូច | ៣០០ x ៨០ | ២៤.០០០ | ៣០ | ១៥ |
| អន្លង់ជ្រៃ | ៨០ x ១០ | ៨០០ | ២០ | ១២ |
| អន្លង់សូក្រ | ៣០០ x ៨០ | ២៤.០០០ | ១៨ | ៨ |
| កោះអន្លង់ត្រីក្រាយ | ៩០ x ៩០ | ៨.១០០ | ៣០ | ២០ |
| អន្លង់ផូង | ៥០ x ៥០ | ២.៥០០ | ២០ | ១២ |
| អន្លង់ខ្លី | ១០០ x ៥០ | ៥០.០០០ | ២០ | ១០ |

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន១អន្លង់ គឺអន្លង់អាចម៍ក្រពើ តាមការសម្រេចរបស់មហាសន្និបាតសហគមន៍នេសាទអូររុន។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់អាចម៍ក្រពើ | ២៥០ x ៨០ | ២.០០០ | ៥០ | ៤០ |

**ឃ.ធនធានជលផល**

**ឃ.១.ប្រភេទត្រី៖**

ត្រីរស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ច្រវ៉ា កំភ្លាញ ឆ្លូញ ខ្មាន់ ឆ្កិន ច្រកែង កន្ទ្រប់ ត្រីដំរី កញ្ចុះ ក្រុះ កញ្ជ្រូក កាហែរ ត្រីលេញ ទ្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឬស្សី ត្រីខ្ទឹង ត្រីខ្យា ត្រីកេះ ឆ្តោក ត្រីកែ ត្រីក្រសក់ ត្រីអណ្តែង ត្រីក្អែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីក្លាំងហាយ ត្រីក្របី ត្រីគ្រំ ត្រីកំបុតច្រមុះ ត្រីខ្យាឃ្មុំ...។

**ឃ.២.ប្រភេទវារីសត្វ៖**

ក្តាម ខ្យង់ ខ្ចៅ គ្រុម លៀស ពស់ កំពិស កង្កែប ហ៊ីង គីង្គក់...។

**ឃ.៣.ប្រភេទសត្វបក្សី**

កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ វនាលខ្យង ក្អែកទឹក ក្អែកគោក...។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖**

ដើមត្រែង ដើមអញ្ចែង ដើមរំចេក ដើមអណ្ដែង ដើមត្រស់ ដើមរាំង ដើមល្វា ដើមថ្នាទឹក ដើមក្ដុល ដើមជ្រៃ....។

## ៤.ការធ្វើនេសាទ

**ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៨៨គ្រួសារ ស្មើ២៤១នាក់ ស្រី១២៥នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មាន២២គ្រួសារ ស្មើ៤៤នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន៤០គ្រួសារស្មើ៨០នាក់ស្រី២០។

**ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ អ្នកមិនចូលជាសមាជិក និងអ្នកនេសាទមកពីក្រៅសហគមន៍៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ / ប្រវែង | | | រដូវប្រើប្រាស់ ឧបករ[redacted] |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | |
| មង | ម៉ែត្រ | ១៣០គ្រួសារ × ១៨០ម = ២៣.៤០០ម | ២២គ្រួសារ ×១០០ម= ២.២០០ម | ៤០គ្រួសារ× ២០០ម =៨.០០០ម | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១៣០គ្រួសារ× ១វង់=១៣០ វង់ | ២២គ្រួសារ × ១វង់=២២វង់ | ៤០គ្រួសារ × ១វង់=៤០ វង់ | ក្រឡា១,៥-៧ស.ម សំរុង ៣.៥-៥,៥ម | ក្រឡា១,៥-៧ស.មសំរុង ៣.៥-៥,៥ម | គ្មាន | ពេញមួយឆ្នាំ |
| សន្ទូច | ផ្លែ | ៨០គ្រួសារ× ១៥០ផ្លែ= ១២.០០០ផ្លែ | ២២គ្រួសារ × ១០០ផ្លែ =២.២០០ផ្លែ | ៤០គ្រួសារ× ១០០ផ្លែ =៤.០០០ផ្លែ | ផ្លែលេខ ១២-៥ | ផ្លែលេខ ១២-៥ | ផ្លែលេខ ១២-៥ | ពេញមួយឆ្នាំ |
| លប | គ្រឿង | ៥០គ្រួសារ × ១០គ្រឿង =៥០០គ្រឿង | ៩គ្រួសារ × ៥គ្រឿង = ៤៥គ្រឿង | គ្មាន | មុខកាត់ ០,៣០ម ប្រវែង ១ម | មុខកាត់ ០,៣០ម ប្រវែង ១ម | គ្មាន | វស្សា |
| ចាន់ | គ្រឿង | ៥០គ្រួសារ× ១៥គ្រឿង= ៧៥០ គ្រឿង | ៩គ្រួសារ× ៥គ្រឿង = ៤៥គ្រឿង | គ្មាន | មុខកាត់ ៤០ស.ម ប្រវែង១,៣ម | មុខកាត់ ៤០ ស.ម ប្រវែង១,៣ម | គ្មាន | វស្សា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ស្វាង | គ្រឿង | ១០គ្រួសារ× ២=២០គ្រឿង | ៩គ្រួសារ× ១=០៩គ្រឿង | គ្មាន | មុខកាត់១ម ប្រវែង៥ម | មុខកាត់១ម ប្រវែង៥ម | គ្មាន | ពេញមួយឆ្នាំ |
| ស្ទូរ | គ្រឿង | ១០គ្រួសារ× ១=១០គ្រឿង | ៩គ្រួសារ× ១=០៩គ្រឿង | គ្មាន | ប្រវែង ៣ម | ប្រវែង ៣ម | គ្មាន | ពេញមួយឆ្នាំ |

ប្រភេទទូកកាណូត

| ប្រភេទកាណូត | ចំនួន (គ្រឿង) | | | ចំណុះ (គីឡូក្រាម) | | | កំលាំង(សេះ) | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអេវជាប់ម៉ាស៊ីន HONDA | ១៥០ | ២២ | ៤០ | ១០០-៤០០ | ១០០-៥០០ | ៣០០-៥០០ | ៦-៨-១៣ | ៨-១៣ | ១៣ |
| ទូកអុំ ចែវ | ១០ | ០ | ០ | ១០០-១៥០ | ០ | ០ | ០ | ០ | ០ |

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០៥ |
| សរុប | | | ១.៦៦១,០៥ |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនវិស័យ

សហគមន៍នេសាទអូររុន មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនៈវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ ។

### គ.គោលបំណងជាក់លាក់

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍មុខរបរចម្រុះ

- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

**ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**ឃ.១.ធនធានជលផល និងអេកូឡូស៊ី**

**ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទឧបករណ៍ នេសាទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ រដូវនេសាទ និងត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| កន្លែងនេសាទសហគមន៍អូររុន | នេសាទពេញ១ឆ្នាំជាលក្ខណៈគ្រួសារ | មង | ក្រឡា២-១២ស.មជម្រៅ៣-៥ម | ១៨០ម៉ែត្រ/គ្រួសារ | |
| | | សំណាញ់ | ក្រឡា១,៥-៧ស.ម សំរុង៣,៥-៥,៥ម | ១វង់/គ្រួសារ | |
| | | សន្ទូច | ផ្លែលេខ១២-៥ | ១៥០ផ្លែ/គ្រួសារ | |
| | | លប | មុខកាត់ ០,៣០ម ប្រវែង ១ម | ១០គ្រឿង/គ្រួសារ | |
| | | ចាន់ | មុខកាត់៤០ស.មប្រវែង១.៣ម | ១៥គ្រឿង/គ្រួសារ | |
| | | ស្ទាង | មុខកាត់ ៥០ស.ម ប្រវែង២,៥ម | ១គ្រឿង/គ្រួសារ | |
| | | ស្ទូរ | មុខកាត់៧០ស.ម ប្រវែង ៧០ស.ម | ១គ្រឿង/គ្រួសារ | |
| -អូរក្ដុល<br>-អូររុន<br>-អូរតាហាក់<br>-អូរតាឈើ<br>-អូរល្វា<br>-អូរឃេ<br>-អូរតាគឹម<br>-អូរគម | ខែ៨ - ខែ១២ | មង | ក្រឡា២-១២ស.មជម្រៅ៣-៥ម | ១៨០ម៉ែត្រ/គ្រួសារ | |
| | | សំណាញ់ | ក្រឡា១,៥-៧ស.ម សំរុង៣,៥-៥.៥ម | ១វង់/គ្រួសារ | |
| | | សន្ទូច | ផ្លែលេខ១២-៥ | ១៥០ផ្លែ/គ្រួសារ | |
| | | លប | មុខកាត់ ០,៣០ម ប្រវែង ១ម | ១០គ្រឿង/គ្រួសារ | |
| | | ចាន់ | មុខកាត់៤០ស.មប្រវែង១.៣ម | ១៥គ្រឿង/គ្រួសារ | |
| | | ស្ទាង | មុខកាត់ ៥០ស.ម ប្រវែង២,៥ម | ១គ្រឿង/គ្រួសារ | |
| | | ស្ទូរ | មុខកាត់៧០ស.ម ប្រវែង ៧០ស.ម | ១គ្រឿង/គ្រួសារ | |

**ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទ**

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្ដើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍អូររុន ១.៣៣៦ ហិកតា | បង្គោលព្រំធ្វើពីស៊ីម៉ងត៍ចំនួន៨បង្គោល | - ផលិតបង្គោលព្រំ<br>- រៀបចំក្រុមចុះបោះបង្គោលព្រំ<br>- ផ្សព្វផ្សាយជាសាធារណៈ | ៦០០ | -គណៈកម្មការ<br>-សមាជិក<br>-មេភូមិ | ២០២០ | ២០២២ |
| | ផ្ទាំងប៉ាណូដែនទីធ្វើពីដែក២ផ្ទាំង | - ផលិតផ្ទាំងប៉ាណូដែនទី<br>- ចុះបោះផ្ទាំងប៉ាណូដែនទី | ៥០០ | -គណៈកម្មការ<br>-សមាជិក | ២០២០ | ២០២២ |
| | ស្លាកអប់រំ៣០ស្លាក | ចុះបោះស្លាកក្នុងដែននេសាទសហគមន៍ | ១២០ | គណៈកម្មការ | ២០២០ | ២០២០ |



**ឃ.១.៣ ផែនការកំណត់ [redacted] រៀបចំកន្លែង [redacted] ក្ស**

ផែនការរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូចខាងក្រោម៖

### ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទ/បរិមាណ | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន៣០គ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់លក្ខណៈគ្រួសារ<br>-អនុវត្តជាក់ស្តែងជាមួយគ្រួសារកសិករធ្វើទ្រុង ផ្តល់ពូជចិញ្ចឹម<br>-តាមដានត្រួតពិនិត្យជាប្រចាំ | ពូជក្នុងស្រុក ១គ្រួសារទទួលបានមាន់៥ក្បាល សរុប៧៥ក្បាល | ៤.៥០០ | ២០២០ | ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន២០គ្រួសារ | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសកសិករ<br>- រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | ពូជក្នុងស្រុក | ៤.០០០ | ២០២០ | ២០២២ |
| ដាំបន្លែជាលក្ខណៈកសិកម្មវ័យឆ្លាត ចំនួន ១៥ គ្រួសារ | -ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- បណ្តុះបណ្តាលបច្ចេកទេសដាំ<br>- ផ្តល់គ្រាប់ពូជ រៀបចំដាំ<br>- តាមដានត្រួតពិនិត្យការថែទាំ | គ្រាប់ពូជបន្លែ(ស្ពៃ ត្រកួន ត្រសក់ សណ្តែក ត្រប់) | ៣.០០០ | ២០២០ | ២០២២ |
| ៣០គ្រួសារបង្កើតធនាគារក្របី | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- បង្កើតគោលការណ៍ប្រើប្រាស់<br>- រៀបចំក្រុម និងផ្តល់មេក្របី<br>- តាមដានត្រួតពិនិត្យជាប្រចាំ | ពូជក្របីក្នុងស្រុក | ៣.៣០០ | ២០២០ | ២០២២ |

### ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណកូនត្រី | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្ដើម | បញ្ចប់ |
| ចិញ្ចឹមត្រីអណ្ដែងក្នុងស្រះតាមបច្ចេកទេសលក្ខណៈគ្រួសារ (១៥ គ្រួសារ) | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំស្រះ ដាក់កូនត្រី<br>- បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមត្រី<br>- ត្រួតពិនិត្យ ធ្វើសំណាក | ១៥ស្រះទំហំ ៥ម×១០ម | ៧.៥០០ ក្បាល/១៥ គ្រួសារ | ៧.៥០០ | ២០២០ | ២០២២ |

### ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| សាងសង់បង្គន់អនាម័យ ៥០គ្រួសារ | ៧.៥០០ | ២០២០ | ២០២២ |
| សាងសង់អណ្ដូងស្នប់ ២អណ្ដូង | ១.០០០ | ២០២០ | ២០២២ |
| ផ្ដល់ធុងចម្រោះទឹក ៥០ ធុង | ២.៥០០ | ២០២០ | ២០២២ |

### ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ

ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផែនការបង្ការ និងបន្សាំភាពធន់និងការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបង្ការដល់ប្រជាជន | ១០០ | ២០២០ | ២០២២ |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | ២០០ | ២០២០ | ២០២២ |
| | កំណត់ រៀបចំទីទួលសុវត្ថិភាព | ១០០ | ២០២០ | ២០២២ |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | ១០០ | ២០២០ | ២០២២ |
| | ផ្ដល់វគ្គបណ្ដុះបណ្ដាលស្ដីពីការបន្សាំការប្រែប្រួលអាកាសធាតុ | ១០០ | ២០២០ | ២០២២ |
| | ចងក្រងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិជាបណ្ដាញដើម្បីចែករំលែកពត៌មាន | ១០០ | ២០២០ | ២០២២ |

### ឃ.៣. ការងារគ្រប់គ្រង

#### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សហគមន៍នេសាទចុះល្បាតដោយខ្លួនឯង | ៣ដង/១ខែ | ១.០៨០ | ២០២០ | ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅសហគមន៍ | ២ដង/១ខែ | ៩០០ | ២០២០ | ២០២២ |
| ទិញទូកស្ពាច់ និងម៉ាស៊ីនកំលាំង ១៣សេះ | ១ គ្រឿង | ១.២០០ | ២០២០ | ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍នេសាទទំហំ ៤ម×៥ម | ១ ខ្នង | ៦០០ | ២០២០ | ២០២២ |

#### ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដង/១ឆ្នាំ | ៣៤០ | ២០២០ | ២០២២ |
| ចូលរួមប្រជុំប្រចាំខែ ឬត្រីមាស ជាមួយក្រុមប្រឹក្សាឃុំ | ១២ដង/១ឆ្នាំ | ៣៤០ | | |
| បណ្ដុះបណ្ដាលពីការសរសេរកំណត់ហេតុ របាយការណ៍ | ១ដង/១ឆ្នាំ | ២០០ | | |
| បណ្ដុះបណ្ដាលការគ្រប់គ្រងថវិកា និងបញ្ជីស្មាម | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំ | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្ដុះបណ្ដាលដោះស្រាយទំនាស់ វិធីសាស្ត្រចុះល្បាត | ១ដង/១ឆ្នាំ | ២០០ | | |
| បណ្ដុះបណ្ដាលច្បាប់ស្ដីពីតំបន់ការពារ ច្បាប់ជលផល | ១ដង/១ឆ្នាំ | ១៥០ | | |
| ទស្សនៈកិច្ចសិក្សាក្រៅខេត្ត | ១ដង/១ឆ្នាំ | ១.០០០ | | |
| បណ្ដុះបណ្ដាលពីការសរសេរគម្រោងស្នើសុំថវិកា | ១ដង/១ឆ្នាំ | ២០០ | | |

#### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួនដង | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២/១ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ២/១ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ច្បាប់ស្ដីពីជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ២/១ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយច្បាប់ស្ដីពីតំបន់ការពារធនធានធម្មជាតិ | ១/១ឆ្នាំ | ៣០០ | ២០២០ | ២០២២ |

| | | | | |
|---|---|---|---|---|
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍ធនធានជលផល | ១/១ឆ្នាំ | ៣០០ | ២០២០ | ២០២២ |
| យុទ្ធនាការប្រមូលឧបករណ៍នេសាទខុសច្បាប់ | ១/១ឆ្នាំ | ១៥០ | ២០២០ | ២០២២ |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៣០០ | ២០២០ | ២០២២ | - គណៈកម្មការ<br>- អាជ្ញាធរឃុំ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៥០ | ២០២០ | ២០២២ | |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | ចុះប្រមូលប្រាក់សមាជិកភាពចំនួន ១.០០០/នាក់នៃសមាជិកសរុប៥៤២នាក់ | ២០២០ | ២០២២ | ១៣៥,៥ | |
| ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍នេសាទ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំចំនួន ២.០០០/គ្រួសារ នៃសមាជិកសរុប ១៨៨គ្រួសារ | ២០២០ | ២០២២ | ២៨២ | |
| ភាគទានពីអ្នកនេសាទក្រៅសហគមន៍ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅចំនួន៤០នាក់(១០.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ៣០០ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាចំនួន២២នាក់ (៥.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ៨២.៥ | |
| **សរុបថវិកាដែលសហគមន៍មាន** | | | | ៨០០ | |

| | | | | | |
|---|---|---|---|---|---|
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែន រដ្ឋាភិបាល និងសប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០២០ | ២០២២ | ៨៤.៦៥០ | |
| **សរុបការចំណាយសហគមន៍នេសាទ** | | | | **៨៥.៤៥០** | |

**ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | ៣០០ | ២០២០ | ២០២២ | -គណៈកម្មការ<br>-អាជ្ញាធរឃុំ |

**ច.យុទ្ធសាស្ត្រ**

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម:

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញអង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការគ្រប់គ្រង
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ

- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច ៤0% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- លើកទឹកចិត្តស្ត្រីជាគណៈកម្មការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ។

### តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អូររុន រយៈពេល៣ឆ្នាំ (២០២០ ដល់ ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១.ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ២ដង ក្នុង១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៦០០<br>១ដង×៨០×២លើក×៣ឆ្នាំ | -សហគមន៍នេសាទ<br>-រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | ផលិតបង្គោលព្រំធ្វើពីស៊ីម៉ង់ត៍ចំនួន៨បង្គោលដាក់នៅតាមព្រំប្រទល់ដែននេសាទអូររុន | - បង្គោលចំនួន៨ដើមត្រូវបានផលិតនិងបានបោះនៅតាមព្រំប្រទល់<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់ | ៦០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ដំឡើងផ្ទាំងប៉ាណូផែនទីចំនួន២ផ្ទាំង | ផ្ទាំងប៉ាណូផែនទីចំនួន២ផ្ទាំងបានផលិត និងបានបោះនៅក្នុងសហគមន៍ | ៥០០ | | ២០២០ | ២០២២ | |
| | ស្លាកអប់រំចំនួន៣០ស្លាក | ស្លាកអប់រំត្រូវបានផលិត និងបានបោះនៅក្នុងសហគមន៍នេសាទ | ១២០ | | ២០២០ | ២០២២ | |
| ឃ.១.៣.ការកំណត់និងរៀបចំតំបន់អភិរក្សអន្លង់អាចម៍ក្រពើ | - ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងសារៈប្រយោជន៍កន្លែងអភិរក្ស<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស៤ទង់<br>- ដាក់ផ្លាកនៅអន្លង់អភិរក្សចំនួន៣០<br>- ដាក់ផ្លាកប៉ាណូផែនទីអន្លង់១ផ្ទាំង<br>- ចុះល្បាតការពារជាប្រចាំនៅអន្លង់អភិរក្ស | - ត្រី និងសត្វគ្រប់ប្រភេទ នឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍<br>-ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស និងបានដឹងពីព្រំប្រទល់កន្លែងអភិរក្សនិងចូលអភិរក្ស | ៥២០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| ឃ.១.៤.ផែនការគ្រប់គ្រងការពារព្រៃលិចទឹក | - ផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សាការពារព្រៃលិចទឹកចម្រុះ | -ព្រៃលិចទឹកកើនឡើងវិញ<br>-ធនធានត្រីមានការកើនឡើងវិញ | ៣០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | - ចុះល្បាតការពារជាប្រចាំ | | | | | | |
| ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់ ចំនួន៣០គ្រួសារ | ៤.៥០០ | -រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូកចំនួន២០គ្រួសារ | ៤.០០០ | | ២០២០ | ២០២២ | |
| | ដាំបន្លែជាលក្ខណៈកសិកម្មវ៉យឆ្លាត | មានគ្រួសារដាំបន្លែចំនួន១៥ គ្រួសារ | ៣.០០០ | | ២០២០ | ២០២២ | |
| | បង្កើតធនាគារក្របីក្នុងសហគមន៍ | មានគ្រួសារ៣០ ចូលរួមបង្កើត | ៣.៣០០ | | ២០២០ | ២០២២ | |
| ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមត្រីអណ្តែងចំនួន១៥គ្រួសារ | ៧.៥០០ | -រដ្ឋបាលជលផល<br>-អង្គការនានា | ២០២០ | ២០២២ | |
| ឃ.២.៣. ផែនការសេវាសហគមន៍និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច | សាងសង់បង្គន់អនាម័យ | មានបង្គន់អនាម័យចំនួន៣០ បានសាង សង់ជូនសមាជិក៣០គ្រួសារ | ៧.៥០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | សាងសងអណ្តូងស្នប់ | អណ្តូងស្នប់២កន្លែងត្រូវបានសាងសង់ | ២.០០០ | | ២០២០ | ២០២២ | |
| | ផ្តល់ធុងចម្រោះទឹក | មានធុងចម្រោះចំនួន៥០ធុង | ២.៥០០ | | ២០២០ | ២០២២ | |
| ឃ.២.៤.ផែនការបង្ការនិងបន្សុំាការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបង្ការដល់ប្រជាពលរដ្ឋក្នុងសហគមន៍ | គណៈកម្មការ និងសមាជិកមានការយល់ដឹងពីផលប៉ះពាល់ពីការប្រែប្រួលអាកាស ធាតុ និងរបៀបបង្ការ | ១០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | មានបង្គោលវាស់កំពល់ទឹកចំនួន១ | ២០០ | | ២០២០ | ២០២២ | |
| | កំណត់រៀបចំទីទួលសុវត្ថិភាព | មានកន្លែងទីទួលសុវត្ថភាពចំនួន១ | ១០០ | | ២០២០ | ២០២២ | |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | បានរៀបចំសិក្ខាសាលាពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | ១០០ | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ផ្ដល់វគ្គបណ្ដុះបណ្ដាលស្ដីពីការបន្សាំការប្រែប្រួលអាកាសធាតុ | គណៈកម្មការមានចំណេះដឹងទាក់ទងនិងការប្រែប្រួលអាកាសធាតុ | ២០០ | | ២០២០ | ២០២២ | |
| | ចងក្រងបណ្ដាញគណៈកម្មការគ្រោះមហន្តរាយតាមភូមិដែលមានស្រាប់ | បានរៀបចំចងក្រងបណ្ដាញគ្រោះមហន្តរាយនៅក្នុងភូមិ | ១០០ | | ២០២០ | ២០២២ | |
| **ឃ.៣. ការគ្រប់គ្រង** | | | | | | | |
| **ឃ.៣.១.ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | សហគមន៍នេសាទចុះល្បាតដោយខ្លួនឯង | បានចុះល្បាត៣ដង/ខែ | ១.០៨០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើស | បានចុះល្បាត២ដង/១ខែសហការជាមួយអាជ្ញាធរមូលដ្ឋាន | ៩០០ | | ២០២០ | ២០២២ | |
| | ទិញទូកស្នាច់និងម៉ាស៊ីនកំលាំង១៣សេះ | មានទូក១ ម៉ាស៊ីន ចំនួន១គ្រឿង | ១.២០០ | | ២០២០ | ២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍នេសាទ | សហគមន៍នេសាទមានស្នាក់ការសម្រាប់ធ្វើការ | ៦០០ | | ២០២០ | ២០២២ | |
| **ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ** | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | បានប្រជុំ១ដង/១ខែ ជាមួយគណៈកម្មការ និងសមាជិក | ៣៤០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ<br>-សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ចូលរួម១ដង/១ខែជាមួយឃុំ | ៣៤០ | | ២០២០ | ២០២២ | |
| | បណ្ដុះបណ្ដាលពីការសរសេររបាយការណ៍ កំណត់ហេតុ | -មានវគ្គបណ្ដុះបណ្ដាលលើមុខជំនាញនីមួយៗ១លើក/១ឆ្នាំ | ២០០ | | ២០២០ | ២០២២ | |
| | បណ្ដុះបណ្ដាលអំពីការគ្រប់គ្រងថវិកា និងបញ្ជីរស្នាម | -សមត្ថភាពសហគមន៍នេសាទបានល្អប្រសើរ | ២៥០ | | ២០២០ | ២០២២ | |
| | បណ្ដុះបណ្ដាលពង្រឹងសមត្ថភាពភាពជាអ្នកដឹកនាំ សម្របសម្រួល | -គណៈកម្មការសហគមន៍នេសាទអាចអនុវត្តន៍បាន | ២៥០ | | ២០២០ | ២០២២ | |
| | បណ្ដុះបណ្ដាលដោះស្រាយទំនាស់ វិធីសាស្ត្រចុះល្បាត | -គណៈកម្មការបានយល់ដឹងពីច្បាប់<br>-គណៈកម្មការយល់ច្បាស់ពីវិធី | ២០០ | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | បណ្តុះបណ្តាលច្បាប់ស្តីពីតំបន់ការពារ ច្បាប់ជលផល | សាស្ត្រក្នុងការចុះល្បាត បង្ក្រាបបទល្មើស | ១៥០ | | ២០២០ | ២០២២ | |
| | ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្រៅខេត្ត | -បានទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍១លើក/១ឆ្នាំ<br>-បានទទួលនូវបទពិសោធន៍ល្អៗ | ១.០០០ | | ២០២០ | ២០២២ | |
| ឃ.៣.៣.ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ<br>-សហគមន៍<br>-នេសាទ | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៣០០ | | ២០២០ | ២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍ធនធានជលផល | បានរៀបចំយុទ្ធនាការ១ដង/ឆ្នាំ | ២០០ | | ២០២០ | ២០២២ | |
| | ប្រមូលឧបករណ៍នេសាទខុសច្បាប់ | បានរៀបចំយុទ្ធនាការ១ដង/ឆ្នាំ | ១៥០ | | ២០២០ | ២០២២ | |
| ឃ.៣.៤.ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍នេសាទតាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | បានផ្សព្វផ្សាយ ២ដង/ឆ្នាំបានបញ្ចូលសកម្មភាពផែនការគ្រប់គ្រងរបស់សហគមន៍នេសាទទៅក្នុងផែនការកម្មវិធីវិនិយោគឃុំ | ១៥០ | អង្គការដៃគូ<br>រដ្ឋបាលជលផល<br>អាជ្ញាធរឃុំ | ២០២០ | ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | ២០២០ | ២០២២ | |
| ឃ.៣.៥.ផែនការ | ភាគទានពីសមាជិកភាព | សមាជិកបានបង់ភាគទាន | | -អង្គការដៃគូ | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ថវិកា ទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | ភាគទានពីសមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | សមាជិកសហគមន៍បានបង់ភាគទានប្រចាំឆ្នាំ១ឆ្នាំម្តង | ចំណូល ១៣៥,៥ | -រដ្ឋបាលជលផល<br>-អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២២ | |
| | ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមកពីខាងក្រៅ | ចំណូល ៣០០ | | ២០២០ | ២០២២ | |
| | | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ | ចំណូល ៨២,៥ | | ២០២០ | ២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ(ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន) | សហគន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពស្របច្បាប់ផ្សេងៗ | | | ២០២០ | ២០២២ | |
| ង.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី និងអ្នកពាក់ព័ន្ធ | -បានប្រជុំមហាសន្និបាត ១ដង/ឆ្នាំ<br>-ធ្វើសេចក្តីរាយការណ៍ពីលទ្ធផលការងារ និងលើកផែនការបន្ត | ១០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២២ | |

## តារាងកម្ម ការងាររយៈពេល៣ឆ្នាំ ( ២០២០- ២០២២ )

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ឃ.១. ធនធានជលផល និងអេកូឡូស៊ី** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | × | | | | | | × | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | |
| **ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផលិតបង្គោលព្រំចំនួន៨បង្គោល | | | | | | | | | | × | × | × | × | | | | | | | | | | | | | | | | | | | | | | | |
| បោះបង្គោលព្រំប្រទល់ | | | | | | | | | | | | | | × | × | × | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទចំនួន២ផ្ទាំង | | | | | | | | | | | × | × | | | | | | | | | | | | | | | × | × | | | | | | | | |
| បោះស្លាកអប់រំចំនួន៣០ស្លាក | | | | | | | × | × | × | | | | | | | | | | | | | × | × | × | | | | | | | | | | | | |
| **ឃ.១.៣.ផែនការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់ព្រះសាខន** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីអន្លង់អភិរក្ស និងសារៈប្រយោជន៍ | × | | | | | | × | | | | | | | | × | | | | | | | | × | | | | | | | | | × | | | | |
| បោះទង់សម្គាល់ព្រំអន្លង់អភិរក្សចំនួន៤ទង់ | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ស្លាកសញ្ញា៣០ស្លាក | | | | | | | | × | × | | | | | | | | | | × | × | | | | | | | | | × | × | | | | | | |
| ដាក់ផ្លាកប៉ាណូផែនទី១ផ្ទាំង | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ឃ.១.៤. ផែនការគ្រប់គ្រង ការពារព្រៃលិចទឹក** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយអោយបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក | | | | | × | | | | | | | | × | | | | | | × | | | | | | × | | | | | × | | | | | | |
| ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹកចំនួន១០ស្លាក | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | × | × | × | × | | | | | | | | | × | × | × | × | | | | | | | | | × | × | × | × | | | | | |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | | | | | × | × | × | × | | | | | | | | | × | × | × | × | | | | | | | | × | × | × | × |
| ដាំបន្លែតាមលក្ខណៈកសិកម្មវ៉ាយឆ្លាត | × | × | × | | | | | | | | × | × | × | × | × | | | | | | | | | × | × | × | × | × | | | | | | | | |
| បង្កើតធនាគារក្របី | | | | | | × | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះជាលក្ខណៈគ្រួសារ | | | | | | | | | × | × | × | | | | | | | | | | × | × | × | | | | | | | | | | × | × | × | |
| **ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សាងសង់បង្គន់អនាម័យ | | | | × | × | × | × | × | | | | | | | | | | | | × | × | × | × | × | | | | | | | | | | | | |
| សាងសង់អណ្តូងស្នប់ | | | | | | | | | × | × | × | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្គត់ផ្គង់ចម្រោះទឹក | | | | | | | | | × | × | × | | | | | | | | | | | × | × | × | | | | | | | | | × | × | × | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការផ្សេងៗ | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | |
| រៀបចំបង្គោលវាស់កម្ពស់ទឹក | | | | | | | | | | × | × | | | | | | | | | | | | × | × | | | | | | | | | | × | × | |
| កំណត់ រៀបចំទីទួលសុវត្ថិភាព | | | | | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | |
| ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | |
| ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | | | × |
| ចងក្រងជាបណ្តាញក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | | | | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | |
| **ឃ.៣. ការងារគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយខ្លួនឯង | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ទិញទូកស្តាច់ម៉ាស៊ីន | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| សាងសង់ទីស្នាក់ការស.ន | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការនេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| បណ្តុះបណ្តាលពីការសរសេររបាយការណ៍ កំណត់ហេតុ | | | | | | × | | | | | | | | | | | | | × | | | | | | | | | | | × | | | | | | |
| បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា និងបញ្ជីស្នាម | | | | | | | | | | | × | | | | | | | | | × | | | | | | | | | | | × | | | | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំនិងសម្របសម្រួល | | | | | | | × | | | | | | | | | | | | | | × | | | | | | | | | | | × | | | | |
| បណ្តុះបណ្តាលដោះស្រាយទំនាស់ វិធីសាស្រ្តចុះល្បាត | | | | | | | | | | × | × | | | | | | | | | | | | | | | × | × | | | | | | | | | |
| បណ្តុះបណ្តាលច្បាប់ស្តីពីតំបន់ការពារ និងច្បាប់ស្តីពីជលផល | | | | | | | × | | | | | | | | | | | | × | | | | | | | | | | | | | | | × | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្រៅខេត្ត | | | | | | | | | | × | | | | | | | | | | | | | | | | | | | | × | | | | | | |
| **ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | × | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | × | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | |
| ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | |
| ផ្សព្វផ្សាយច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | | |
| យុទ្ធនាការប្រមូលឧបករណ៍នេសាទខុសច្បាប់ | | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | |
| **ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈ បុណ្យទាន សន្និបាតប្រចាំឆ្នាំ | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | × | × | × | | | | | | | | | | × | × | × | | | | | | | | | | × | × | × | | | | | | | | | |
| **ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ភាគទានប្រចាំឆ្នាំពីសមាជិក | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រាក់បដិភាគអ្នកនេសាទខាងក្រៅសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ប្រាក់បដិភាគមិនមែនជាសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ប្រាក់ចំណូលពីប្រភពផ្សេងៗ** (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែន រដ្ឋាភិបាល និងអំណោយពីសប្បុរសជន) | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំមហាសន្និបាតសហគមន៍នេសាទ | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | |

លេខ..៤០.....[illegible]......
បានឃើញ និងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ.........[illegible].........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង,ថ្ងៃទី.........ខែ.........ឆ្នាំ២០១៩
**នាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់**

លេខ..[illegible]..../១៩ បរ.ផ.ស
បានឃើញ និងបញ្ជូនមក
លោកនាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ.........[illegible].........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
អូរស្វាយ,ថ្ងៃទី.........ខែ.........ឆ្នាំ២០១៩
**មេឃុំអូរស្វាយ**

សេក ហៅ

សូមគោរពជូន
លោកមេឃុំអូរស្វាយ
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ.........[illegible].........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ភូមិអូររុន,ថ្ងៃទី២[illegible].....ខែ..១១.....ឆ្នាំ២០១៩
**ប្រធានគណៈកម្មការសហគមន៍នេសាទអូររុន**

លេខ.........................
បានឃើញ និងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីពិនិត្យ និងសម្រេចដោយអនុគ្រោះ"
ថ្ងៃ.........................ខែ.............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង ថ្ងៃទី......២៣......ខែ......៩......ឆ្នាំ២០១៩
**ប្រធាន**
**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង**

ល្មៀង_សេង

លេខ.........................
បានឃើញ និងគោរពជូន
លោកប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ.........................ខែ.............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង ថ្ងៃទី......០៦......ខែ......៩......ឆ្នាំ២០១៩
**នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង**

ទុំ នីរ៉ូ

លេខ......................... 
បានឃើញ និងឯកភាព
ថ្ងៃ.........................ខែ.............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី......១៧......ខែ.............ឆ្នាំ២០២០
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន